**អង្គការមិត្តសំឡាញ់**

**កម្មវិធីទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍**

**ថ្ងៃច័ន្ទ ទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១២**

ឆ្នាំនេះអង្គការមិត្តសំឡាញ់បានសំរេចប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ក្រោមប្រធានបទ« ២០១៥! គ្មានការចម្លងមេរោគអេដស៍ពីម្តាយទៅកូន» ក្នុងគោលបំណងដើម្បីចូលរួមកាត់បន្ថយការឆ្លងរីករាលដាលនៃមេរោគអេដស៍ជំងឺអេដស៍សំដៅចូលរួមឆ្លើយតបទៅនឹងយុទ្ធសាស្រ្តថ្នាក់ជាតិរបស់រាជរដ្ឋាភិបាល។

កម្មវិធីនេះនឹងត្រូវបានចូលរួមពីកុមារ/យុវវ័យមកពីតាមផ្ទល់ សហគមន៍កុមារ/យុវវ័យមកពីអង្គការ ដៃគូរនានា តំណាងដៃគូរអភិវឌ្ឍ តំណាងភ្នាក់ងាររដ្ឋាភិបាល ម្ចាស់ជំនួយនិងអាជ្ញាធរដែនដីដែលមានចំនួនសរុបប្រមាណ៩០០នាក់។

ជាមួយនេះដែរដើម្បីញ៉ាំងកម្មវិធីឲ្យកាន់តែមានភាពសប្បាយរីករាយនិងទាក់ទាញចំណាប់អារម្មណ៍ក្នុងការចូលរួមពីកុមារ/យុវវ័យ យើងបានរៀបចំនូវសកម្មភាពមួយចំនួនដូចខាងក្រោម:

- ពីម៉ោង៩.០០- ព្រឹក-៤.០០រសៀល: ការចូលរួមផាត់ពណ៌និងគូរគំនូរដោយកុមារនិងយុវវ័យនៅផ្ទាំងក្រណាត់នៅក្នុងកង់ទីន។
- ពីម៉ោង២.០០ ដល់ម៉ោង៣.១០នាទី: កម្មវិធីសិល្បៈ
- ពីម៉ោង៣.១០ ដល់ម៉ោង៣.២០នាទី: ការបង្ហាញអំពីអត្ថន័យផ្ទាំងគំនូរអ្នកចូលរួមគូរ
- ពីម៉ោង៣.២០ ដល់ម៉ោង៤.០០នាទី: កម្មវិធីសំនួរចម្លើយ និងល្បែងកំសាន្ត

កម្មវិធីនេះអាចដំណើការទៅបានដោយមានការឧបត្ថមថវិកាពីម្ចាស់ជំនួយDCA/CA និងឧបត្ថមបច្ចេកទេសពីអង្គការ Friends International។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកមិត្តសំឡាញ់និង Friends International ដែលបានការហាការល្អក្នុងការរៀបចំកម្មវិធីនេះ ឲ្យទទួលបានជោគជ័យ ជាពិសេសអាជ្ញាធរដែនដីអង្គការដៃគូរដែលបានចូលរួម និងប្រព័ន្ធផ្សព្វផ្សាយនានាដែលបានជួយចាក់ផ្សាយកម្មវិធីយើងខ្ញុំ។

សូមអរគុណ